# គម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី៣
# ករណីសិក្សា

| | |
|---|---|
| **ស៊ី.ស៊ី.ចេប/ផ្នែក៖**<br>*ទប់ស្កាត់បទល្មើស និងរក្សាសុវត្ថិភាពសហគមន៍*<br>**បុគ្គលបំពេញទំរង់បែបបទ៖**<br>*ឈ្មោះ ៖ និតសោភ័ណ*<br>*តួនាទី ៖ គណៈកម្មការគ្រប់គ្រងគម្រោង* | **កាលបរិច្ឆេទ៖** *ខែមេសា ឆ្នាំ២០១១*<br>**អ្នកដែលត្រូវបានសម្ភាសន៍៖**<br>*ឈ្មោះ ៖ ឡោកសុផាន់ អាយុ៖ ៣៥ ឆ្នាំ*<br>*ភេទ៖ ស្រី*<br>*ភូមិ៖ តាអុងកើត* **ឃុំ៖** *រលួស* **ស្រុក៖**<br>*ស្វាយចេក* **ខេត្ត៖** *បន្ទាយមានជ័យ* |

**ទិសដៅ**

*យុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រ៤នៃកម្មវិធីទប់ស្កាត់បទល្មើស និងសុវត្ថិភាព សហគមន៍ (ទ.ប.ស.ស) គឺការលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ និងជំរុញឲ្យមានឥរិយាបថល្អៗ សម្រាប់សង្គមតាមរយៈការផ្តល់សេវាផ្នែកសង្គម ផ្នែកសេដ្ឋកិច្ច និងអប់រំ ដោយផ្តោតជាពិសេសទៅ លើក្រុមអនីតិជន និងយុវជនដែលមានឥរិយាបថអាចពាក់ព័ន្ធទៅនឹងបទល្មើស ឬរងគ្រោះដោយសារបទល្មើស ។ ករណីសិក្សាខាងក្រោមនេះ គឺជាឧទាហរណ៍មួយនៃការគាំទ្ររបស់គម្រោង ស៊ី.ស៊ី.ចេប ដែលបានចូលរួមចំណែកធ្វើអោយសហគម៌មានភាពរុងរឿងប្រកបដោយបរិស្ថានសុវត្ថិភាព និងសន្តិសុខល្អ។*

**ដំណើររឿង**

*បងស្រី **ឡោក សុផាន់** អាយុ៣៥ឆ្នាំ រស់នៅជាមួយប្តីឈ្មោះ **ញាន ពៅ** អាយុ២៩ឆ្នាំ មានកូនប្រុស២នាក់។ អ្នកទាំងពីរចាប់ផ្តើមទំនាក់ទំនងស្រលាញ់គ្នាខ្លាំងណាស់នៅឆ្នាំ២០០៣ ហើយចេះជួយធ្វើការងារគ្នាទៅវិញទៅមក។ ប៉ុន្តែគ្រួសារនេះមានជីវភាពមិនធូរធារទេដោយពឹងផ្អែកលើដីស្រែចំនួន៣រ៉ៃប៉ុណ្ណោះ។ អ្នកទាំងពីរតែងតែនាំគ្នាទៅស៊ីឈ្នួលដកស្ទូងតាមទម្លាប់របស់អ្នកស្រែ។ ក្រៅពីរដូវធ្វើស្រែប្តីគាត់ធ្វើជាកម្មករសំណង់។*

*បងស្រី **ឡោក សុផាន់** បានឲ្យដឹងថានៅឆ្នាំ២០០៥ គ្រួសាររបស់គាត់ចាប់ផ្តើមមានអំពើហិង្សាក្នុងគ្រួសារដោយសារប្តីគាត់ចាប់ផ្តើមចេះផឹកស្រា។ គាត់ផឹកស្រាកាន់តែច្រើនឡើង និងខ្លាំងឡើងជាលំដាប់ជាមួយមិត្តភក្តិគាត់ ហើយគាត់ស្រវឹងស្ទើតែរាល់ថ្ងៃៗនៅពេលស្រវឹងមកដល់ផ្ទះប្តីគាត់ឈ្លោះប្រកែកវាយចានឆ្នាំងបែកបាក់ពាសពេញផ្ទះ និងចោទគាត់ថាមានសាហាយៗ គ្មាននរណាអាចជួយ*

*ឃាត់គាត់តើបានទេ។ ការនិយាយហាមឃាត់បន្តិចបន្តួចនោះនឹងបង្កឲ្យមានជំលោះភ្លាម។ បងស្រី **ឡោក សុផាន់** បាននិយាយបន្តថា គាត់មិនអាចតដៃជាមួយប្តីគាត់វិញបានឡើយ ពីព្រោះគាត់គ្មានកម្លាំងនឹងតតាំងជាមួយប្តីគាត់វិញទេ។*

*ជាឧទាហរណ៍ ជួនពេលមួយនោះគាត់កំពុងតែបោកសំលៀកបំពាក់ស្រាប់តែប្តីរបស់គាត់មកធាក់គាត់ដោយពុំដឹងខ្លួនសោះធ្វើឲ្យគាត់ដួលផ្កាប់មុខទៅលើដី ហើយប្តីគាត់ក៏ដើរចេញបាត់ទៅ។ ឧទាហរណ៍មួយទៀត គាត់កំពុងដាក់ឆ្នាំងដាំបាយពេលល្ងាចស្របពេលដែលប្តីរបស់គាត់ត្រឡប់មកពីស្រែវិញ ប្តីគាត់ពុំបាននិយាយអ្វីទាល់តែសោះស្រាប់តែស្ទុះមកវាយគាត់តែម្តងដោយពុំមានមូលហេតុ។*

*ទោះបីជាយ៉ាងនេះក៏ដោយ គាត់នៅតែរក្សាភាពស្ងាត់ស្ងៀមមិនប្រាប់នរណាម្នាក់ទេ។ គាត់សង្ឃឹមថាថ្ងៃណាមួយ គាត់អាចនិយាយជាមួយប្តីរបស់គាត់ស្ងាត់ស្ងៀមដើម្បីជៀសវាងកុំឲ្យមានបញ្ហានេះកើតឡើងម្តងទៀត។*

*បើទោះបីជាមេភូមិ និងមេឃុំបានហៅទៅអប់រំក៏ដោយ ក៏ប្តីគាត់នៅតែមិនស្តាប់និងមិនឈប់ប្រព្រឹត្តនូវអំពើនោះដែរ។ ដូច្នេះហើយ ការរកប្រាក់ចំណូលសម្រាប់គ្រួសាររបស់គាត់កាន់តែពិបាក ពីព្រោះប្តីគាត់កាន់តែទៅផឹកស្រា ហើយមិនបានជួយធ្វើការងារឡើយ។ ចំពោះគាត់ ជាប់មានកូនតូចអាយុ១ខួប ហើយមិនអាចទៅធ្វើការងារបាន។*

*ប្តីគាត់ "**លោក ញាន ពៅ**" បានយកលេសភាពស្រវឹងរបស់គាត់មកប្រព្រឹត្តអំពើហិង្សានេះ ហើយបានបន្តរហូតជាច្រើនខែមកហើយ។ បងស្រី **ឡោក សុផាន់** តែងតែគិតថាក្នុងមួយជីវិតរបស់គាត់ គ្រួសារគាត់ជួបតែនឹងអំពើហិង្សារហូត។ ភាពរីករាយដូចគ្រួសារដទៃទៀតប្រហែលជាមិនមានឡើយ។*

*បញ្ហាចំបងដែលគាត់បារម្ភណ៍នោះគឺកូនរបស់គាត់ទាំងពីរដែលទើបតែមានអាយុ៦ឆ្នាំ និង២ឆ្នាំ ដែលពួកគេត្រូវការភាពកក់ក្តៅពីឪពុកម្តាយ។ ដើម្បីកូនតូចទាំងពីរ គាត់សុខចិត្តទ្រាំតាមកម្មវាសនាបានកំណត់ទៅចុះ។*



## ការជួយអន្តរាគមន៍

*នៅក្នុងឆ្នាំ២០១០ បងស្រី **ឡោក សុផាន់** បានចូលរួមស្តាប់អំពីការផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារដែលធ្វើការផ្សព្វផ្សាយដោយការិយាល័យកិច្ចការនារីស្រុក ដោយមានការគាំទ្រថវិកាពីកម្មវិធីទប់ស្កាត់បទ*

ល្មើស និងសុវត្ថិភាពសហគមន៍នៃគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី៣ (គម្រោង ស៊ីស៊ីចេប)។ ក្នុងអំឡុងពេលផ្សព្វផ្សាយនោះ មេភូមិ និងគាត់ក៏បានអញ្ជើញប្ដីគាត់ឲ្យទៅចូលរួមស្ដាប់នឹងគេ ក៏ប៉ុន្តែប្ដីគាត់មិនបានចូលរួមទេ។ ក្រោយពីបានទទួលការផ្សព្វផ្សាយ គាត់បាននិយាយប្រាប់ប្ដីគាត់នូវខ្លឹមសារមួយចំនួនអំពីច្បាប់ (អ្នកដែលប្រព្រឹត្តហិង្សាក្នុងគ្រួសារបង្ករឲ្យមានរបួសស្នាមត្រូវទទួលទោសព្រហ្មទណ្ឌ) ដែលគាត់ស្ដាប់បាន និងយល់ដឹងខ្លះៗ ក្នុងគោលបំណងឲ្យប្ដីគាត់ខ្លាច និងបន្ថយ ឬឈប់បង្ករឲ្យមានអំពើហិង្សាក្នុងគ្រួសារនេះតទៅទៀត។

ប៉ុន្តែ វាហាក់ដូចជាមិនបានទទួលផលប្រយោជន៍អ្វីសោះ ប្ដីគាត់មិនស្ដាប់ ហើយថែមទាំងបន្តការប្រព្រឹត្តនូវអំពើហិង្សាដដែល។ ក្រោយមកលោកមេភូមិ ឃុំ និងការិយាល័យកិច្ចការនារីស្រុកបានចុះទៅអប់រំផ្ទាល់ដល់ប្ដីគាត់ ដោយមានការពិគ្រោះយោបល់ផ្ដល់ព័ត៌មានពីការគាំទ្ររបស់កម្មវិធី ទ.ប.ស.ស នៃគម្រោង ស៊ីស៊ីចេប ស្ដីពីការលើកទឹកចិត្ត និងរកនូវបញ្ហាដែលប្ដីគាត់តែងតែជួបប្រទះ តើមានអ្វីដែលអាចជួយកាត់បន្ថយបញ្ហាទាំងនោះបាន។ ក្រោយមកប្ដីគាត់បានកាត់បន្ថយការវាយតប់គាត់ ប៉ុន្តែការជេរបញ្ចោ និងបោកចាន បោកឆ្នាំងនៅតែកើតមាន។

នៅខែមីនា ឆ្នាំ២០១០ លោកមេឃុំ និងមន្ត្រីកិច្ចការនារីស្រុកបានទៅពន្យល់ម្ដងទៀតពីការគាំទ្ររបស់គម្រោងនូវជម្រើសនានាទាក់ទងទៅនឹងវិជ្ជាជីវៈ ដូចជាការបណ្ដុះផ្សិត ការចិញ្ចឹមជ្រូកអ៊ុតសក់ និងកាត់ដេរ ។ល។ ក្នុងគោលបំណងជួយដោះស្រាយនូវបញ្ហា និងជីវភាពគ្រួសារដែលជួបនូវអំពើហិង្សានេះ។ ក្រោយមក**ប្ដីគាត់ "លោក ញាន ពៅ"** ក៏បានយល់ព្រមឲ្យគាត់ចូលរួមវគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈ កាត់ដេរដោយមានការជួយគាំទ្រពីគម្រោងទាំងថវិកា និងស្មារតី និងមានការប្ដេជ្ញាចិត្តខ្ពស់ពីប្ដីរបស់គាត់ក្នុងការជួយកិច្ចការផ្ទះមួយចំនួនៗ ដូច្នេះ អាចធ្វើឲ្យគាត់ចូលរួមវគ្គនេះបាន។

## ការផ្លាស់ប្ដូរឥរិយាបថ

ក្នុងរយៈពេលវគ្គបណ្ដុះបណ្ដាល៦ខែ បងស្រី **ឡោក សុផាន់** សង្កេតឃើញថាប្ដីរបស់គាត់បានជួយកិច្ចការផ្ទះបានច្រើនមែន ដូចជាដាំបាយ មើលថែកូន និងកិច្ចការផ្សេងៗទៀតដែលធ្វើឲ្យគាត់អាចបានរៀនវគ្គកាត់ដេរនេះបានជោគជ័យ និងឃើញថាអំពើហិង្សាក្នុងគ្រួសារក៏បានថយចុះមួយកម្រិត ទោះបីជាគាត់មានការផឹកស៊ីម្ដងម្កាលក៏ដោយ។

ក្រោយពីគាត់បានបញ្ចប់វគ្គបណ្ដុះបណ្ដាល គម្រោងនៅតែបន្តគាំទ្រដោយបានឧបត្ថម្ភសំភារៈកាត់ដេរ ដូចជាម៉ាស៊ីនដេរ និងក្រណាត់ដើម្បីធ្វើជាដើមទុនបន្តសម្រាប់បង្កើតមុខរបរផ្គត់ផ្គង់ជីវភាពគ្រួសារ។

*ឥឡូវនេះ បងស្រី **ឡោក សុផាន់** បានបើកមុខរបរកាត់ដេរក្នុងផ្ទះខ្លួនឯង ហើយមុខរបរនេះអាចបង្កើនប្រាក់ចំណូលបានមួយកម្រិត។ ក្នុងខែដំបូង ជាមធ្យម មានអ្នកមកកាត់ដេរមានចំនួន **១០ ទៅ ១៥នាក់**។ បងស្រី **ឡោកសុផាន់** បញ្ជាក់បន្ថែមទៀតថា ការកាត់ដេរនេះដាច់គួរសមដែរ ពីព្រោះគាត់យកតម្លៃទាបជាងទីផ្សារដើម្បីទាក់ទាញអតិថិជនដំបូង និងបង្កើនបទពិសោធន៍កាត់ដេរនេះឲ្យរឹតតែប្រសើរឡើង។*

*បងស្រី **ឡោក សុផាន់** សប្បាយចិត្តណាស់នៅពេលដែលគ្រួសាររបស់គាត់អាចរកចំណូលបាន ហើយប្តីរបស់គាត់ក៏អាចជួយការងារបានផងដែរ។ ប្តីរបស់គាត់បានក្លាយជាមនុស្សល្អ អ្នកភូមិរាប់អាន និងស្រលាញ់ប្តីគាត់ដូចគេឯង ពីព្រោះប្តីគាត់ឈប់ស្រែកឡូឡារំខានដល់អ្នកភូមិទៀត។*

*លោក **រី ថន** ប្រធានភូមិ និងបងស្រី **ឡុង ជួត** សមាជិកភូមិ ក៏បានអះអាងផងដែរថា ក្រុមគ្រួសារប្តីប្រពន្ធប្អូន **ឡោកសុផាន់** មានការផ្លាស់ប្តូរជាវិជ្ជមាន ដោយសារប្អូនស្រី **ឡោក សុផាន់** រវល់នឹងការរៀនសូត្រកាត់ដេរច្រើន។ ចំណែក លោក ញានពៅ ដែលជាប្តីពិតជាបានជួយធ្វើកិច្ចការផ្ទះច្រើនជំនួសប្រពន្ធដូចដែលបានសន្យាពីខាងដើមមែន។*



*អ្នកមីង **ឆន ចន្ថា** ជាអ្នកជិតខាងក៏បានឲ្យដឹងថា គ្រួសារក្មួយស្រី **ឡោក សុផាន់** មានការកាត់បន្ថយការឈ្លោះប្រកែកគ្នាបានច្រើន ឈប់ឮសូរការវាយតប់គ្នា ជេរគ្នា បោកចានបោកឆ្នាំងស្រវឹងដេកពាសវាលពាសកាលទៀតហើយ។*

*ខាងលើនេះបង្ហាញឲ្យឃើញថា កម្មវិធី ទ.ប.ស.ស នៃគម្រោងជំនួយផ្នែកព្រហ្មទណ្ឌនិងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី៣ ពិតជាមានឥទ្ធិពលវិជ្ជមាន ពីព្រោះគម្រោងបានជួយទាំងស្មារតីកែប្រែអត្តចរិក ឥរិយាបថ និងជួយជីវភាពគ្រួសារឲ្យបានធូរធារ និងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារដែលជួយស្តារនិងកាត់បន្ថយភាពក្រីក្រ ជាពិសេសដូចជាគ្រួសារបងស្រី ឡោក សុផាន់ ជាដើម៕*